ភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែសីហា ឆ្នាំ២០១៦



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រចាំខែសីហា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមាន ចូលរួមរបស់ឯកឧត្តម-លោកស្រីអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន សាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល និងជាប្រធានអង្គប្រជុំ បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម-លោកស្រីអគ្គនាយករង លោក-លោកស្រី មន្ត្រីរាជការពន្ធដារទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ និងសូមសម្តែងនូវការអរគុណ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ក្នុងខែសីហា ឆ្នាំ២០១៦ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលពន្ធ-អាករគ្រប់ប្រភេទបានចំនួន ៤៨៣ ២៥៩,៥០ លានរៀល (ប្រមាណជា ១២០,៨១ លានដុល្លារ)។ សម្រាប់រយៈពេល ០៨ខែ ឆ្នាំ២០១៦ ប្រមូលចំណូលពន្ធ-អាករ សរុបបានចំនួន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

៤ ៣០៣ ៧៩៦,៣៨ លានរៀល ប្រមាណជា ១ ០៧៥,៩៥ លានដុល្លារ) ស្មើនឹង ៧៥,៦៩% នៃគោលដៅកំណត់ដោយច្បាប់។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៥ ឃើញថា ការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ សម្រាប់រយៈពេល ០៨ខែ ឆ្នាំ២០១៦ កើនឡើងចំនួន ៧១៧ ៥២៧,៥៧ លានរៀល (ប្រមាណ ១៧៩,៣៨ លានដុល្លារ) ឬស្មើនឹងអត្រាកំណើន ២០,០១%។

ក្នុងរយៈពេលដូចគ្នានេះដែរ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា មានការកើនឡើងផងដែរ នូវចំណូលពន្ធ-អាករ តាមប្រភេទពន្ធសំខាន់ៗមួយចំនួនដូចជា៖ ពន្ធលើប្រាក់ចំណេញ មានការកើនឡើងចំនួន ២២,៦%, ពន្ធលើប្រាក់បៀវត្ស មានការកើនឡើងចំនួន ២៥,៨%, អាករលើតម្លៃបន្ថែមកើនឡើងចំនួន ២១,៩%, អាករពិសេសកើនឡើងចំនួន ២២,១%។

ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំ បានផ្តល់នូវអនុសាសន៍ណែនាំដល់អង្គភាពពន្ធដារ ក្រោមឱវាទទាំងអស់របស់អគ្គនាយកដ្ឋានពន្ធដារ ឲ្យបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូលពន្ធ ជាពិសេស ផ្តោតជាសំខាន់លើកិច្ចការមួយចំនួនដូចខាងក្រោម៖

-ពង្រឹងការគ្រប់គ្រង ការអនុវត្តវិធានវិក្កយបត្ររបស់បណ្តាសហគ្រាសនានា

-បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃសេវាសាធារណៈជូនអ្នកជាប់ពន្ធ

-បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម របស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តជំរុញការគ្រប់គ្រង និងផ្សព្វផ្សាយអំពីការធ្វើបច្ចុប្បន្នភាពអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ និងពង្រឹងការប្រមូលពន្ធប្រភេទនេះសម្រាប់ឆ្នាំ២០១៦ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត

-បន្តពង្រឹងការប្រមូលពន្ធ លើការជួលអចលនទ្រព្យ (ដី-ផ្ទះ) តាមរយៈការដាក់ឲ្យអនុវត្តការគ្រប់គ្រង ការប្រកាសបង់ពន្ធប្រភេទនេះ តាមប្រព័ន្ធកុំព្យូទ័រថ្មី

-គ្រោងនឹងបោះពុម្ពបណ្ណសម្គាល់ ការបង់ពន្ធលើអចលនទ្រព្យ ដូចគ្នានឹងបណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដែលបានបោះពុម្ពកន្លងមក ដើម្បីសម្រួលដល់ការបង់ពន្ធរបស់អ្នកជាប់ពន្ធ នៅបណ្តាឆ្នាំបន្តបន្ទាប់ខាងមុខ

-ចុះអង្កេតស្រាវជ្រាវសហគ្រាស (Street Survey) ក្នុងរាជធានីភ្នំពេញដោយផ្តើមពីខណ្ឌចំការមនដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬមិនព្រមមកចុះបញ្ជីពន្ធដារ ឲ្យមកចុះបញ្ជីពន្ធដារ បានគ្រប់គ្នា

-ពង្រឹងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦

-ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងពង្រឹងសមត្ថភាពមន្ត្រី ដើម្បីក្លាយជាមន្ត្រីដែលពោរពេញដោយសមត្ថភាព ជំនាញ និងទេពកោសល្យ។ ព្រមជាមួយនេះ ត្រូវប្រើឲ្យបានអស់សក្តានុពល នូវធនធានមន្ត្រីដែលមានស្រាប់

-ពង្រឹងការដាក់លិខិតប្រកាស នៅនាយកដ្ឋានថ្នាក់កណ្តាល ក៏ដូចជាតាមសាខាពន្ធដារខេត្ត-ខណ្ឌនីមួយៗ

-ពិនិត្យ ផ្ទៀងផ្ទាត់ឲ្យបានម៉ត់ចត់ ចំពោះការស្នើសុំបង្វិលសង របស់សហគ្រាសនានា



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

-ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស ជាពិសេស នៅតាមសហគ្រាសផលិតផលិតផលជាប់អាករពិសេស

-យកចិត្តទុកដាក់ខ្ពស់ ចំពោះការស្នើសុំផ្ទេរសហគ្រាស ដោយត្រូវអនុវត្តតាមសេចក្ដីណែនាំដែលកំពុងមានជាធរមាន

-បន្តពង្រឹងការធ្វើសវនកម្មលើសហគ្រាស ជាពិសេស សហគ្រាសដែលប្រកាសពន្ធទាប មិនសមស្របនឹងស្ថានភាពជាក់ស្ដែងនៃអាជីវកម្មរបស់ខ្លួន

-បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Data Base) ដែលមានលក្ខណៈល្អប្រសើរ ដើម្បីងាយស្រួល ក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធ

-បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្ដីពីសារពើពន្ធ ក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីប្រព័ន្ធពន្ធដារកម្ពុជា ទាំងនៅរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌទូទាំងប្រទេស

-បន្តចូលរួមយ៉ាងសកម្ម ក្នុងគោលនយោបាយកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបានលទ្ធផល កាន់តែប្រសើរថែមទៀត។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំបានវាយតម្លៃខ្ពស់ ចំពោះលទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធរបស់អង្គភាពក្រោមឱវាទទាំងអស់ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូល រហូតទទួលបានលទ្ធផលគួរជាទីមោទនៈ និងបានផ្ដល់អនុសាសន៍ណែនាំបន្ថែមដល់គ្រប់អង្គភាព ឲ្យបន្តខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ផ្អែកទិដ្ឋភាពច្បាប់ ក្នុងការឆ្លើយតបទៅកាន់អ្នកជាប់ពន្ធ ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធសប្បាយចិត្ត មិនសម្ដែងការរអ៊ូរទាំ និងផ្ដល់កិច្ចសហការល្អក្នុងការបង់ពន្ធជូនរដ្ឋ។


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ